# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការសាលាឧទ្ធរណ៍
លេខ ៣១១/២០០០

## អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

**សូមជម្រាបមក**

## ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**សូមជ្រាប។**

**តាមរយៈ:** ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងយុតិធម៌

**កម្មវត្ថុ:** ស្តីពីការទទួលក្មេងខិលខូចមកអប់រំកែប្រែនៅមជ្ឍមណ្ឌលយុវនីតិសម្បទា ។

**យោង:** លិខិតលេខ ៦៣ ព.ន.គ ២០០០ ចុះថ្ងៃទី១១-០៤-២០០០ របស់ការិយាល័យពន្ធនាគារស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមជ្រាប អំពីការិយាល័យពន្ធនាគារស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានបញ្ជូនឈ្មោះគង់ រតនា ជាអនីតិជនភេទប្រុសទៅក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាល និងយុវនីតិសម្បទា តាមអំណាចសាលដីកាសាលាឧទ្ធរណ៍ភ្នំពេញ លេខ ២៧ ចុះថ្ងៃទី២១-០១-២០០០ ដែលបានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌចំណុចទី ២ នៃសាលក្រមលេខ ២៣ ធ ចុះថ្ងៃទី១៧-០៥-៩៩ របស់តុលាការក្រុងភ្នំពេញ ដែលសម្រេចបញ្ជូនឈ្មោះគង់ រតនា ភេទប្រុស អាយុ១២ឆ្នាំ១០ខែ ៩ថ្ងៃ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥៩ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ របររកស៊ីសិស្សថ្នាក់ទី៦ នៅសាលាសន្ធរម៉ុក,ឪពុកឈ្មោះគង់ គីម (ស)ម្តាយឈ្មោះញឹក ចន្ត្រី (រ) ទោសពីមុនគ្មាន ទៅក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាដើម្បីធ្វើការអប់រំកែប្រែរយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃនេះតទៅ។ ប៉ុន្តែក្រសួងសង្គមកិច្ចការងារបណ្តុះ បណ្តាលវិជ្ជាជីវៈនិងយុវនីតីសម្បទាមិនព្រមទទួលយកដោយហេតុថា រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ប្រគល់ភារកិច្ចជូនក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ទទួលបន្ទុកគ្រប់គ្រងអប់រំតែកុមារខិលខូចប៉ុណ្ណោះ ចំណែកកុមារ ដែលតុលាការសម្រេចអំពីកំហុសហើយតម្រូវឱ្យមានការអប់រំបង្ហាត់បង្រៀនមិនអាចទទួលយកបានទេ

ធ្វើនៅភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០០